# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៩ អនក្រ.បក

ជាតិ សាសនា ព្រះមហាក្សត្រ

## អនុក្រឹត្យ

## ស្តីពី

## បទវិន័យទូទៅសំរាប់ កងយោធពលខេមរភូមិន្ទ

\+ + + + +

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពី លក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ

-បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងការពារជាតិ

-បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០១

## សំរេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ កំណត់បទវិន័យទូទៅ សំរាប់កងយោធពលខេមរភូមិន្ទនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ២.-**

អនុក្រឹត្យនេះមានវិសាលភាព អនុវត្តចំពោះកងយោធពលខេមរភូមិន្ទ គ្រប់ប្រភេទ គ្រប់ឋានានុក្រម និងគ្រប់លំដាប់ឋានន្តរស័ក្តិ ។

កងយោធពលខេមរភូមិន្ទ ត្រូវមានភក្តីភាពចំពោះ ជាតិ សាសនា ព្រះមហាក្សត្រ និងបំពេញការងារទៅតាមឋានានុក្រម ។

## ជំពូកទី ២

## ឋានានុក្រម និង បទបញ្ជា

**មាត្រា ៣.-**

ឋានានុក្រមនៃកងយោធពលខេមរភូមិន្ទ ត្រូវផ្អែកលើមូលដ្ឋាននៃរចនាសម្ព័ន្ធដែលបានកំណត់នូវមុខនាទីនីមួយៗ និងភារកិច្ចទទួលខុសត្រូវរបស់ខ្លួន តាមលំដាប់ឋានន្តរស័ក្តិ ។

ឋានានុក្រមរបស់កងយោធពលខេមរភូមិន្ទមានដូចតទៅ :

- ពលទាហាន
- នាយទាហានរង
- នាយទាហាន

យោធិនគ្រប់រូប ក្នុងកិច្ចបំពេញការងាររបស់ខ្លួន ត្រូវចំណុះគ្នាពីមួយទៅមួយតាមលំដាប់ឋានានុក្រម លើកលែង តែមានច្បាប់ដោយឡែកពីនេះ ដាក់អោយប្រើប្រាស់ជាធរមាន ។

ការគោរពតាមលំដាប់នៃឋានានុក្រម មានដូចខាងក្រោម :

- ក្នុងករណីឋានន្តរស័ក្តិស្មើគ្នា ត្រូវគិតពីអតីតភាពនៃឋានន្តរស័ក្តិ
- ក្នុងករណីអតីតភាពនៃឋានន្តរស័ក្តិស្មើគ្នាទៀត ត្រូវគិតពីអតីតភាពនៃឋានន្តរស័ក្តិមុន ។

**មាត្រា ៤.-**

អ្នកដឹកនាំគ្រប់ជាន់ថ្នាក់មានសិទ្ធិគ្រប់គ្រាន់ ក្នុងការគ្រប់គ្រង ដឹកនាំ បញ្ជា សំរេចលើការងារ ក្នុងក្របខ័ណ្ឌ តួនាទី ភារកិច្ចរបស់ខ្លួន ។ យោធិនគ្រប់រូប ដែលបំពេញមុខងារក្នុងឋានៈជាបណ្តោះអាសន្ន ឬ ស្តីទី ដែលថ្នាក់ដឹកនាំ បានប្រគល់សិទ្ធិអោយមានសិទ្ធិអំណាច និង ការទទួលខុសត្រូវ ក្នុងមុខងាររបស់ខ្លួនដូចពេញសិទ្ធិដែរ ។

ឃ

អ្នកដឹកនាំគ្រប់ជាន់ថ្នាក់អាចប្រគល់អំណាច មួយចំនួនទៅអ្នកដែលស្ថិតនៅក្រោមបញ្ជារបស់ខ្លួន បានទៅតាមការកំណត់នៃបទបញ្ជារបស់កងយោធពលខេមរភូមិន្ទ។

**មាត្រា ៥.-**

បញ្ជារបស់អ្នកដឹកនាំគ្រប់ជាន់ថ្នាក់ត្រូវអោយយោធិន ឬកងឯកភាពចំណុះទាំងឡាយអនុវត្តដោយផ្ទាល់ ដោយចំពោះ និងដោយពេញលេញ។

ក្នុងករណីអ្នកដឹកនាំនៃកងឯកភាពមួយមិនអាចបំពេញមុខងាររបស់ខ្លួនបាន ក្នុងស្ថានភាពណាមួយត្រូវចាត់តាំងអ្នកជំនួសដោយលាយលក្ខណ៍អក្សរ រហូតដល់ សាមីខ្លួនជាអ្នកដឹកនាំពេញសិទ្ធិ មកកាន់ដំណែងឡើងវិញ។ អវត្តមានរបស់អ្នកដឹកនាំពេញសិទ្ធិត្រូវចុះបញ្ជាក់ក្នុងសៀវភៅ រដ្ឋបាលទុកជាកំណត់-ហេតុ។

អ្នកដឹកនាំស្តីទី ត្រូវទទួលខុសត្រូវ ក្នុងការសំរេចអ្វីៗទាំងអស់ ក្នុងអង្គភាពរបស់ខ្លួន។

## ជំពូកទី ៣

## ករណីយកិច្ច និងការទទួលខុសត្រូវរបស់យោធិន

**មាត្រា ៦.-**

យោធិនគ្រប់រូប មានករណីយកិច្ចក្នុងនាមជានាយអោយបញ្ជាផង និងក្នុងនាមជាអ្នកក្រោមបង្គាប់ទទួលបញ្ជាផង។

ក្រៅពីករណីយកិច្ច និងការទទួលខុសត្រូវផ្ទាល់ ដោយឡែកយោធិនមានកាតព្វកិច្ចរួមដូចតទៅ :

**១-ជាសមាជិកក្នុងកងទ័ព :**

- គោរពបញ្ជា ដែលទទួលស្របតាមការកំណត់របស់ច្បាប់
- មានសេចក្តីទៀងត្រង់និងសេចក្តីថ្លៃថ្នូរប្រកបដោយកិត្តិយស
- ប្រតិបត្តិ តាមបទបញ្ជាយោធា ទោះបីជាសាមីខ្លួនយល់ថាបទបញ្ជានោះពិបាកប្រតិបត្តិតាមដោយប្រការណាមួយក៏ដោយ
- រក្សាការសំងាត់ និងរក្សាពាក្យសំដីជាពិសេសអំពីកិច្ចការយោធា
- ថែទាំ សំភារៈ និង ឋបនីយភ័ណ្ឌទាំងឡាយ របស់យោធាបានប្រគល់ ឬដាក់អោយប្រើប្រាស់

៤

**២-នៅពេលបំពេញភារកិច្ចក្នុងកងឯកភាព :**

-ខិតខំប្រតិបត្តិការងារ ដោយឥតសំចៃកម្លាំងគ្រប់ពេលវេលា

- ខំប្រឹងរៀនសូត្រ ដើម្បីអោយមានសមត្ថភាពក្នុងការបំពេញភារកិច្ច និង ដើម្បីចូលរួមលើកតំលៃ កងឯកភាពរបស់ខ្លួន

- ខំប្រឹងហ្វឹកហាត់ដើម្បីប្រសិទ្ធភាពការងារ

- និងត្រៀមកម្លាំងកាយ កម្លាំងចិត្តក្នុងការប្រយុទ្ធ។

**មាត្រា ៧.-**

ក្នុងឋានៈជានាយ យោធិនត្រូវ :

-មានការសំរេចក្នុងការអោយបញ្ជាដោយម៉ឺងម៉ាត់ និងច្បាស់លាស់ និងតាមដានរាល់ការអនុវត្តនៃបញ្ជាទាំងនោះ

-ទទួលខុសត្រូវចំពោះការអោយបញ្ជាទាំងឡាយ

-គោរពសិទ្ធិអ្នកនៅក្រោមបង្គាប់

-ផ្តល់ពត៌មានសម្ងាត់ ដល់អ្នកនៅក្រោមបង្គាប់ទាំងឡាយ ក្នុងករណីចាំបាច់

-ជូនរង្វាន់ដល់អ្នកមានស្នាដៃ ឬដាក់ទណ្ឌកម្មដល់អ្នកបានធ្វើខុសតាមកំរិតកំហុស នៅក្នុងក្របខ័ណ្ឌមុខងាររបស់ខ្លួន

-កត់សម្គាល់ និងអោយមតិវិចារណ៍ដល់យោធិននៅក្រោមបង្គាប់ ដែលបានបំរើ ឬបំពេញមុខងារជារៀងរាល់ឆ្នាំ ហើយក្រើនរំលឹកពីកំហុសរបស់យោធិនម្នាក់ៗ ដើម្បីអោយគេកែតម្រង់ខ្លួន

-យកចិត្តទុកដាក់ ពីជីវភាពរស់នៅផ្ទាល់របស់អ្នកនៅក្រោមបង្គាប់ ហើយត្រូវរាយការណ៍ទៅស្ថាប័នមានសមត្ថកិច្ចជួយដោះស្រាយ ក្នុងករណីចាំបាច់។

ក្នុងឋានៈជានាយអោយបញ្ជា យោធិនមិនអាចគេចផុតពីការទទួលខុសត្រូវក្នុងការអនុវត្តនៃបញ្ជាណាមួយដែលខ្លួនដាក់ចុះអោយថ្នាក់ក្រោមអនុវត្តនោះឡើយ។

បញ្ជាទាំងឡាយត្រូវតែបញ្ជូនទៅតាមឋានានុក្រម ។ក្នុងករណីបន្ទាន់អាចធ្វើទៅតាមផ្លូវកាត់បាន ប៉ុន្តែត្រូវជូនដំណឹងដល់ថ្នាក់កណ្តាលបន្តបន្ទាប់ដែលពាក់ព័ន្ធ អោយបានជ្រាបផងដែរ ។

**មាត្រា ៨.-**

ការគោរពបញ្ជា គឺជាករណីយកិច្ចចំបងរបស់អ្នកនៅក្រោមបង្គាប់ ។

ក្នុងឋានៈជាអ្នកនៅក្រោមបង្គាប់ យោធិនត្រូវ:

-អនុវត្តដោយភក្ដីភាព នូវបញ្ជាដែលខ្លួនទទួល ហើយទទួលខុសត្រូវផ្ទាល់ចំពោះការអនុវត្តនីបញ្ជានោះ

-មានគំនិតវាងវៃជានិច្ច ក្នុងការអនុវត្តនីបញ្ជានៅគ្រប់កាលៈទេសៈ

រាយការណ៍ជាចាំបាច់ក្រោយពីអនុវត្តរួចនូវបញ្ជានីមួយៗ ។ ក្នុងករណីមិនអាចអនុវត្តបាននូវបញ្ជាដោយប្រការណាមួយត្រូវធ្វើសេចក្ដីរាយការណ៍ជាបន្ទាន់ជូនអ្នកអោយបញ្ជា ។

អ្នកក្រោមបង្គាប់មិនត្រូវអនុវត្តបញ្ជាដោយអាការៈបញ្ចោះបន្ទោកឬអនុវត្តបញ្ជាដែលមានលក្ខណៈផ្ទុយពីច្បាប់សង្គ្រាម ផ្ទុយពីអនុសញ្ញាអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខា ។

អ្នកក្រោមបង្គាប់អនុវត្តមិនត្រឹមត្រូវតាមបញ្ជា ត្រូវទទួលទណ្ឌកម្មផ្នែកវិន័យ និងទទួលទោសតាមច្បាប់ ។

**មាត្រា ៩.-**

យោធិនត្រូវគោរព និងអនុវត្តរាល់បញ្ជាដោយមានស្មារតីទទួលខុសត្រូវ ។ បញ្ជាណាដែលមានភាពច្បាស់ក្រឡែតផ្ទុយពីច្បាប់ ឬផ្ទុយពីអនុសញ្ញាអន្តរជាតិត្រូវហាមឃាត់ ។ ក្នុងករណីនេះអ្នកបញ្ជាក្ដី អ្នកអនុវត្តក្ដី ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ។

យោធិន ដែលមិនអនុវត្តបញ្ជា ដែលខ្លួនយល់ថាមានភាពច្បាស់ក្រឡែតផ្ទុយពីច្បាប់ ឬអនុសញ្ញាអន្តរជាតិ ត្រូវទទួលទោសត្រឹមតែវិន័យយោធា ។ ផ្ទុយទៅវិញ បើខ្លួនអនុវត្តបញ្ជាខុសច្បាប់នោះ យោធិននឹងទទួលខុសត្រូវផ្ទាល់ខ្លួនទាំងផ្នែករដ្ឋប្បវេណី និងផ្នែកព្រហ្មទណ្ឌ ។

**មាត្រា ១០.-**

ក្នុងការប្រយុទ្ធ យោធិនត្រូវ:

-មានសេចក្ដីក្លាហាន ហ៊ានប្រឈមមុខចំពោះគ្រោះថ្នាក់ និងហ៊ានធ្វើពលីកម្មគ្រប់បែបយ៉ាង ដើម្បីសំរេចនូវបេសកកម្ម ដែលខ្លួនទទួល

-រិះរកគ្រប់មធ្យោបាយដើម្បីអោយបានដល់គោលដៅកំណត់ទុក ឬកាន់កាប់ទីតាំងដែលខ្លួនបានទទួលបញ្ជា

-ប្រមូលថែរក្សានូវអាវុធយុទ្ធភ័ណ្ឌ និងសំភារៈទាំងឡាយរបស់មិត្តរួមអាវុធដែល ពលី របួស ឬមានជំងឺ

-ធ្វើយ៉ាងណាកុំអោយសត្រូវចាប់ខ្លួនបាន ខិតខំរកមធ្យោបាយទៅកាន់កងឯកភាព ឬអាជ្ញាធរដែនដី ដែលនៅជិតជាងគេបំផុត ក្នុងករណីមិនអាចប្រយុទ្ធបាន និងជាចំណុចទំនាក់ទំនង ។

ក្នុងកាលៈទេសៈណាក៏ដោយ យោធិនមិនត្រូវ:

-បោះបង់អាវុធយុទ្ធភ័ណ្ឌ និងសំភារៈដែលនៅប្រើការកើត

-សំរុះសំរួលជាមួយសត្រូវ

-ប្រគល់ខ្លួនអោយសត្រូវ មុនពេលប្រយុទ្ធលែងកើត ឬអស់សំភារៈប្រយុទ្ធ

-ប្រព្រឹត្តល្មើសច្បាប់សង្គ្រាម ដែលមានចែងក្នុងសន្ធិសញ្ញាអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខា ។

**មាត្រា ១១.-**

យោធិនជាមេបញ្ជាការត្រូវ :

-ដឹកនាំការប្រយុទ្ធ និងបន្តការប្រយុទ្ធអោយបានសំរេច ឬដឹកនាំការប្រយុទ្ធរហូតដល់ដំណាក់កាលចុងក្រោយ

-ដាស់តឿន ឬលើកទឹកចិត្តក្នុងការប្រយុទ្ធគ្រប់កាលៈទេសៈ ឬក្នុងករណីចាំបាច់ អាចប្រើមធ្យោបាយបង្ខំទៀតផង

-ប្រើគ្រប់មធ្យោបាយ ដើម្បីការពារកុំអោយឯកសារសំខាន់ៗ ឬសំភារៈអាវុធយុទ្ធភ័ណ្ឌធ្លាក់ទៅក្នុងកណ្តាប់ដៃសត្រូវ

-ប្រមូលផ្តុំឡើងវិញនូវកងទ័ព កងឯកភាព ចំណុះបញ្ជាការផ្សេងៗពីគ្នា ដែលត្រូវកាត់ផ្តាច់ការគ្រប់គ្រងបញ្ជាដោយសត្រូវ ដាក់ក្រោមការដឹកនាំបញ្ជារបស់បញ្ជាការថ្មីណាម្នាក់ ដែលមានលំដាប់ឋានន្តរស័ក្តិខ្ពស់ជាងគេ ។

**មាត្រា ១២.-**

ក្នុងករណីមេបញ្ជាការ និងមេបញ្ជាការរងទាំងអស់ត្រូវ ពលី យោធិនដែលមានសមត្ថភាពខ្ពស់ និងក្លាហានជាងគេត្រូវឡើងបញ្ជា ហើយបន្តការប្រយុទ្ធតទៅទៀត ។

ក្នុងករណីធ្លាក់ជាឈ្លើយសឹក យោធិននៅតែស្ថិតជាយោធិនដដែល ។

ក្នុងករណីធ្លាក់ជាឈ្លើយសឹក យោធិនត្រូវរិះរកមធ្យោបាយរត់អោយរួចពីការឃុំឃាំង ដើម្បី រិះរក

វិធីប្រយុទ្ធតបតវិញ ។ក្នុងករណីរត់គេចខ្លួនមិនរួច ត្រូវតែប្តេជ្ញាតស៊ូគ្រប់បែបយ៉ាងចំពោះការគាបសង្កត់របស់សត្រូវ ដោយមិនព្រមផ្តល់ពត៌មានអោយសត្រូវ ហើយត្រូវមានសាមគ្គីភាពជាទិច្ច រវាងមិត្តរួមអាវុធ ព្រមទាំងជួយឧបត្ថម្ភចំពោះអ្នកដែលមានបំណងរត់គេចខ្លួន ទោះបីខ្លួនឯងមិនអាចរត់រួច ដោយជម្ងឺ ឬរបួសក៏ដោយ ។

យោធិនដែលធ្លាក់ជាឈ្លើយសឹក ត្រូវប្រកាន់ខ្ជាប់នូវវិន័យ និង គោរពបញ្ជាតាមឋានានុក្រមជាមួយ នឹងមិត្តរួមអាវុធរបស់ខ្លួន ដែលធ្លាក់ជាឈ្លើយសឹកដូចគ្នា ។

## មាត្រា ១៣.-

ត្រូវហាមឃាត់ដល់យោធិននូវប្រការទាំងឡាយដូចខាងក្រោម :

-សម្លាប់ឈ្លើយសឹក

-បំផ្លាញ ឬប្លន់ទ្រព្យសម្បត្តិប្រជាពលរដ្ឋ

-ចាប់ចងមនុស្សយកទៅធ្វើជាថ្នូរ ដើម្បីផលប្រយោជន៍អ្វីមួយ

-ប្រើអំពើហិង្សាចំពោះប្រជាពលរដ្ឋ ក្នុងពេលដែលខ្លួនបានចូលទៅកាន់កាប់ទីកន្លែងប្រយុទ្ធណាមួយ

-ធ្វើទោសដល់បុគ្គលទាំងឡាយ ដោយគ្មានការវិនិច្ឆ័យពីតុលាការ

-រំលោភបំពានលើរាងកាយអ្នកជម្ងឺ អ្នករបួស អ្នកលង់ទឹក ឈ្លើយសឹក និងប្រជាពលរដ្ឋស៊ីវិល

-ធ្វើឃាត ឬធ្វើទារុណកម្មគ្រប់បែបយ៉ាង

-នែកនេរយកទ្រព្យសម្បត្តិរបស់សាកសព ឬអ្នករបួស ។

## មាត្រា ១៤.-

យោធិនត្រូវថែទាំឈ្លើយសឹកដែលចាប់បានតាមលក្ខណៈមនុស្សធម៌ និងគោរពសិទ្ធិក្នុងការថែរក្សាទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់គេ លើកលែងតែអាវុធយុទ្ធភ័ណ្ឌ ឬឯកសារយោធា ដែលចាំបាច់ត្រូវដកហូត ហើយបញ្ជូនឈ្លើយសឹកទៅកន្លែងប្រមូលផ្តុំក្នុងរយៈពេលខ្លី ។

## មាត្រា ១៥.-

យោធិនជាបុគ្គលិកសុខាភិបាលត្រូវ :

-ចូលរួមក្នុងសកម្មភាពប្រយុទ្ធជាមួយមិត្តរួមអាវុធ

-ជួយមិត្តរួមអាវុធដោយមធ្យោបាយបច្ចេកទេស ដែលខ្លួនមានក្នុងស្មារតីសាមគ្គី

-ទទួលព្យាបាលអ្នករបួស និងអ្នកជម្ងឺ ដោយគ្មានការរើសអើង ភេទ សញ្ជាតិ ពូជសាសន៍ សាសនា និងនិន្នាការផ្សេងៗ

-ត្រូវនៅប្រចាំការជិតអ្នករបួស ប្រសិនជាស្ថានភាពប្រយុទ្ធអនុញ្ញាត ។

ក្នុងករណីត្រូវអោយបោះបង់អ្នកជម្ងឺ ដោយហេតុផលជាចាំបាច់ក្នុងការប្រយុទ្ធ ត្រូវចុះក្នុងបញ្ជីអោយបានត្រឹមត្រូវ ។

## ជំពូកទី ៤

## សិទ្ធិរបស់យោធិន

### មាត្រា ១៦.-

យោធិនគ្រប់រូបមានសិទ្ធិ និងសេរីភាពដូចប្រជាពលរដ្ឋដទៃទៀត ក៏ប៉ុន្តែត្រូវមានអព្យាក្រឹត្យភាពក្នុងការបំពេញមុខនាទីស្របតាមច្បាប់ស្តីពី លក្ខន្តិកៈទូទៅ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ។

ការប្រើសិទ្ធិ និងសេរីភាពខ្លះ ត្រូវហាមឃាត់ :

-សំដែងជាសាធារណៈ នូវគំនិត និងមតិ ឬជំនឿផ្ទាល់ខ្លួនដែលមានលក្ខណៈជាទស្សនៈវិជ្ជាឬនយោបាយ

-ផ្សព្វផ្សាយនូវអ្វីៗ ដែលធ្វើអោយអន្តរាយដល់សីលធម៌ និងវិន័យរបស់កងយោធពលខេមរភូមិន្ទ

-បង្កើតក្រុមវិជ្ជាជីវៈ ដែលមានលក្ខណៈជាសហជីព

-ធ្វើ ឬចូលរួមបាតុកម្ម និងកូដកម្ម ។

យោធិនដែលពីមុនបានបំរើការងារក្នុងស្ថាប័នរដ្ឋបាលស៊ីវិល ហើយបានចូលជាសមាជិកសហជីព ឬសមាជិកគណបក្សនយោបាយ មុនពេលចូលបំរើកងទ័ព អាចនៅជាសមាជិកដដែល ក៏ប៉ុន្តែមិនអាចធ្វើសកម្មភាពនយោបាយ ឬសហជីពក្នុងពេលខ្លួនកំពុងបំពេញមុខងារបច្ចុប្បន្នបានឡើយ ។

### មាត្រា ១៧.-

យោធិនគ្រប់រូបមានសិទ្ធិក្នុងការតវ៉ាចំពោះអ្នកដែលដាក់ទណ្ឌកម្មខ្លួន។ បណ្តឹងតវ៉ានេះត្រូវធ្វើតាម

រយៈនាយផ្ទាល់ ហើយបញ្ជូនតាមឋានានុក្រម ។

ក្នុងរយៈពេល៣ខែ ចាប់ពីថ្ងៃដែលបានចុះក្នុងសៀវភៅតវ៉ានៃកងឯកភាពរបស់ខ្លួនរួចមក បើមិនមានចំលើយពីអ្នកដឹកនាំជាន់ខ្ពស់ សាមីខ្លួនអាចធ្វើលិខិតតវ៉ាទៅស្ថាប័នអធិការកិច្ច ដោយភ្ជាប់នូវសំណុំរឿងរបស់ខ្លួនមកជាមួយផង ។ ក្រោយពេលដែលបានទទួលសំណុំរឿងនេះហើយ ស្ថាប័នអធិការកិច្ច ត្រូវផ្តល់យោបល់ជូនរដ្ឋមន្ត្រីក្រសួងការពារជាតិដើម្បីសំរេច ។

សេចក្តីសំរេចរបស់រដ្ឋមន្ត្រី ត្រូវផ្ញើទៅសាមីជនអ្នកតវ៉ាតាមរយៈស្ថាប័នអធិការកិច្ច ហើយត្រូវចុះក្នុងបញ្ជីតវ៉ាកងឯកភាពនោះផង ។

យោធិនដែលតវ៉ា ដោយប្រឌិតហេតុផលមិនសមស្រប ត្រូវទទួលទណ្ឌកម្មធ្ងន់ថែមទៀត ។

## មាត្រា ១៨.-

យោធិនគ្រប់រូបមានសិទ្ធិសុំច្បាប់ឈប់សំរាករយៈពេលយូរ និងច្បាប់ឈប់សំរាកសំរាប់ធុរៈក្នុងគ្រួសារផ្ទាល់ ។

ក្នុងកាលៈទេសៈចាំបាច់ អ្នកដឹកនាំអាចកោះហៅយោធិនទាំងនោះអោយចូលមកបំរើការងារវិញ ។

## មាត្រា ១៩.-

យោធិនគ្រប់រូប ដែលបានបំរើការជាអចិន្ត្រៃយ៍ក្នុងមុខងារ មានសិទ្ធិសុំច្បាប់ឈប់សំរាក ចំនួន ៤៥ ថ្ងៃក្នុងមួយឆ្នាំតែមួយដង ឬបែងចែកជាច្រើនដង ប៉ុន្តែត្រូវមាន១ដងយ៉ាងតិច ១៥ ថ្ងៃ ។

ការគិតចំនួនថ្ងៃឈប់សំរាកត្រូវកំណត់៤ថ្ងៃក្នុងមួយខែសំរាប់យោធិនដែលមិនបានបំរើការងារពេញមួយឆ្នាំ ។

## មាត្រា ២០.-

យោធិនគ្រប់រូបដែលបានចាត់អោយទៅបំពេញការងារ ឬទៅសិក្សាឯបរទេស ដែលមានរយៈពេលចាប់ពី ៦ខែ ឡើងទៅ អាចសុំច្បាប់ឈប់សំរាកបានមុនពេលបេសកកម្ម ចំនួន ១៥ថ្ងៃ ។ ច្បាប់ឈប់សំរាកនេះ មិនត្រូវលើសពី ៣០ថ្ងៃឡើយ ។

**មាត្រា ២១.-**

យោធិនមានសិទ្ធិសុំច្បាប់ឈប់សំរាកធុរៈគ្រួសារ ។

របៀបបទ និងរយៈពេលឈប់សំរាកត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការពារជាតិ ។

**មាត្រា ២២.-**

យោងតាមការចាំបាច់នៃការងារ យោធិនអាចសុំច្បាប់ឈប់សំរាករយៈពេលខ្លីមិនអោយលើសពី ៧២ម៉ោង ។

**មាត្រា ២៣.-**

សិទ្ធិអនុញ្ញាតច្បាប់ឈប់សំរាកគ្រប់ប្រភេទសំរាប់យោធិន ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការពារជាតិ ។

## ជំពូកទី ៥

## ចនបញ្ញាក្នុងការចាត់តាំងការងារ

**មាត្រា ២៤.-**

ក្រៅពីភារកិច្ចក្នុងកងយោធពលខេមរភូមិន្ទ យោធិនគ្រប់រូបត្រូវចូលរួមក្នុងជីវភាពសង្គម ក្នុងកាលៈទេសៈចាំបាច់ដូចជា ការជួយប្រមូលផលប្រជាពលរដ្ឋ ការជួយប្រជាពលរដ្ឋក្នុងពេលមានគ្រោះមហន្តរាយ ការជួយកសាងហេដ្ឋារចនាសម្ព័ន្ធ និងជួយណែនាំប្រជាពលរដ្ឋតាមភូមិ ឃុំ ស្រុក ខេត្តក្រុង ។ល ។

ការចូលរួមក្នុងជីវភាពនេះត្រូវបានទទួលការចាត់តាំងពីកងឯកភាពអោយបានទាន់ពេលវេលា ។

**មាត្រា ២៥.-**

យោធិនគ្រប់រូបអាចដើរលើរពាសពេញយោធភូមិ ដែលខ្លួនកំពុងនៅបំពេញការងារ ក្នុងករណីចេញក្រៅយោធភូមិ យោធិនត្រូវសុំច្បាប់អនុញ្ញាតពីថ្នាក់លើ ។

ក្នុងកាលៈទេសៈចាំបាច់ សេរីភាពដើរលើររបស់យោធិន អាចត្រូវបានកាត់បន្ថយ ។

យោធិន ដែលស្ថិតក្នុងនាវា នៃកងទ័ពជើងទឹកអាចចាកចេញពីនាវាបានតាមលក្ខខណ្ឌ ដែលកំណត់ដោយបទបញ្ជារបស់មេបញ្ជាការនៃកងទ័ពជើងទឹក ។

យោធិនគ្រប់រូប ត្រូវបានចាត់ទុកដូចជា " បំពេញភារកិច្ច " ក្រោមការទទួលខុសត្រូវរបស់រដ្ឋ :

- ក្នុងពេលធ្វើដំណើរក្នុងបរិវេណយោធា

- ក្នុងពេលធ្វើដំណើរក្នុងផ្លូវធម្មតា ចន្លោះទីកន្លែងដែលយោធិនធ្វើសកម្មភាព និងទីកន្លែងដែលអនុញ្ញាតអោយឈប់សំរាក ឬក្នុងចន្លោះទីកន្លែងធ្វើការងារ និងទីកន្លែងស្នាក់នៅ ។

**មាត្រា ២៦.-**

យោធិននៅក្នុងសាលា ឬក្នុងមជ្ឈមណ្ឌលហ្វឹកហ្វឺន ត្រូវប្រតិបត្តិតាមបទបញ្ជាផ្ទៃក្នុងរបស់សាលា ឬមជ្ឈមណ្ឌលនោះ ។

អ្នកដឹកនាំអាចតំរូវដល់យោធិនដែលតាំងទីលំនៅក្នុងភូមិសាស្ត្រ ដែលបានកំណត់ ឬនៅក្នុងលំនៅឋានដែលជាកម្មសិទ្ធិយោធា ។

យោធិនដែលមានតាំងទីលំនៅក្នុងបរិវេណយោធា ត្រូវគោរពបទបញ្ជាដែលបានចែងទុក សំដៅធានាសន្តិសុខ អនាម័យ និងសណ្តាប់ធ្នាប់ក្នុងការសំរាកស្នាក់នៅ ។

**មាត្រា ២៧.-**

យោធិនគ្រប់រូបក្នុងពេលបំរើការងារ ត្រូវស្លៀកពាក់ឯកសណ្ឋានតាមការកំណត់ជាចាំបាច់ ។ ក្នុងកាលៈទេសៈខ្លះ មេបញ្ជាការអាចអនុញ្ញាត ឬមានបទបញ្ជាអោយស្លៀកពាក់ឯកសណ្ឋានស៊ីវិលក្នុងពេលបំរើការងារ ។

បទបញ្ជាទាំងឡាយដែលផ្ទុយពីបទបញ្ជានេះ អាចអនុញ្ញាតបានដោយមានសេចក្តីសំរេចពីរដ្ឋមន្ត្រីក្រសួងការពារជាតិ ឬតាមបទបញ្ជារបស់អគ្គមេបញ្ជាការ ។

ឯកសណ្ឋាននៃកងយោធពលខេមរភូមិន្ទ ត្រូវកំណត់ដោយអនុក្រឹត្យមួយដោយឡែក ។

យោធិនគ្រប់រូបមិនត្រូវ :

- ស្លៀកពាក់ឯកសណ្ឋានយោធាក្នុងពេលបំរើការងារស៊ីវិល ក្នុងពេលចូលរួមប្រជុំទាំងឡាយ ជាសាធារណៈ ឬឯកជន ដែលមានលក្ខណៈជានយោបាយ ឬបោះឆ្នោតក្នុងសមាគម ឬ សហជីព ។

បើសិនជាមានបញ្ហាពិសេសខ្លះ អាចប្រកាសអោយប្រើតាមបញ្ជារបស់មេបញ្ជាការកងឯកភាព ដោយ

ចាំបាច់ក្នុងកិច្ចបំរើការងារ

- ធ្វើដំណើរដោយគ្មានមួក នៅក្រៅបរិវេណអាគារ និងលូកដៃក្នុងហោប៉ៅខោ ឬអាវ ។ ក៏ប៉ុន្តែពេលធ្វើដំណើរក្នុងអាគារ អាចមិនពាក់មួកបាន ។

ការត្រួតពិនិត្យឯកសណ្ឋាន គឺជាការទទួលខុសត្រូវជាអចិន្ត្រៃយ៍នៅគ្រប់លំដាប់ថ្នាក់នៃឋានានុក្រម ។

នៅក្រៅប្រទេស ឯកសណ្ឋានអនុញ្ញាតអោយស្លៀកពាក់បាន សំរាប់យោធិនទាំងឡាយណាដែល :

- បំរើការក្នុងបេសកកម្មទូត ឬចាត់តាំងជាសមាជិកក្នុងបេសកកម្មបច្ចេកទេស
- មានបេសកកម្មជាផ្លូវការ និងរៀនសូត្រនៅឯបរទេស
- សំចតឆ្លងកាត់រវាងប្រទេសនានា ក្នុងឋានៈជាគណៈប្រតិភូយោធា ដើម្បីទៅកាន់ប្រទេសណាមួយផ្សេងទៀត ។

យោធិនទាំងឡាយដែលស្នាក់នៅឯបរទេស ហើយត្រូវចូលរួមក្នុងពិធីជាផ្លូវការ ឬជាឯកជនអាចស្លៀកពាក់ជាឯកសណ្ឋានយោធាបាន ក្នុងករណីមានការអនុញ្ញាតពីរដ្ឋមន្ត្រី ឬមានការព្រមព្រៀង ពីស្ថានតំណាងទូត នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៨.-**

យោធិនគ្រប់រូប អាចស្លៀកពាក់ឯកសណ្ឋានស៊ីវិលបាននៅក្រោយពេលបំរើការងារ និងក្រៅបន្ទាយយោធា លើកលែងតែក្នុងកាលៈទេសៈខ្លះ ដែលមិនអាចអនុញ្ញាតអោយស្លៀកពាក់បាន ។

អាចអនុញ្ញាតអោយស្លៀកពាក់ស៊ីវិល ក្នុងការសហការអនុវត្តការងារទាំងឡាយ ដែលបានទទួលបន្ទុកជាបណ្តោះអាសន្ន ក្នុងបេសកកម្មខ្លះ ។

ប្រភេទមុខងាររបស់យោធិនគ្រប់រូប ដែលអាចអនុញ្ញាតអោយស្លៀកពាក់ស៊ីវិលបានត្រូវសំរេចដោយរដ្ឋមន្ត្រីក្រសួងការពារជាតិ ឬដោយអគ្គមេបញ្ជាការ ។

ក្នុងលក្ខណៈពិសេស ការអនុញ្ញាតអោយស្លៀកពាក់ឯកសណ្ឋានស៊ីវិលក្នុងម៉ោងធ្វើការ ត្រូវកំណត់ដោយលាយលក្ខណ៍អក្សរ និងសមស្របតាមការណែនាំរបស់ថ្នាក់លើ ។

ក្រៅម៉ោងធ្វើការ យោធិនទាំងឡាយណា ដែលរស់នៅក្នុងបរិវេណយោធា អាចអនុញ្ញាតអោយស្លៀកពាក់ឯកសណ្ឋានស៊ីវិលបាននៅពេលធ្វើដំណើរចេញ ឬចូលមកកាន់កន្លែងវិញ ។

សំលៀកបំពាក់ស៊ីវិលដែលយោធិនស្លៀកពាក់ ត្រូវអោយមានភាពថ្លៃថ្នូរសមរម្យ ។ ហាមស្លៀកពាក់លាយឡំឯកសណ្ឋានយោធាផង ស៊ីវិលផង ឬពាក់កណ្តាលស៊ីវិល ពាក់កណ្តាលយោធា ។

យោធិនគ្រប់រូបជាសិស្សក្នុងសាលាហ្វឹកហ្វឺន បើកាលណាចង់ស្លៀកពាក់ស៊ីវិលក្នុងពេលចេញក្រៅសាលាត្រូវមានការអនុញ្ញាតពីនាយកសាលា តាមការណែនាំពីថ្នាក់លើ ។

**មាត្រា ២៩.-**

ការកាត់សក់ ការទុកក្រចកដៃ ត្រូវធ្វើអោយបានត្រឹមត្រូវតាមក្បួនអនាម័យ សមនិងឯកសណ្ឋានព្រមទាំងសំភារៈបរិក្ខាប្រើប្រាស់ពិសេសផ្សេងទៀត ។ ដូច្នេះចាំបាច់តំរូវអោយមានការកិតប្រវែងសក់ ។

ទ្រង់ទ្រាយសក់ ត្រូវអោយស្របទៅនឹងទ្រង់ទ្រាយក្បាល និងស្ថានភាពសក់របស់បុគ្គលម្នាក់ៗដើម្បីអោយងាយស្រួលក្នុងការសំអាត និងការសំអិតសំអាង ព្រមទាំងអោយមានលក្ខណៈសមរម្យនៅពេលពាក់មួក និងជៀសវាងការមានស្នាមមួកលើសក់ នៅពេលដោះមួកចេញ ។ ដូច្នេះសក់ត្រូវកាត់អោយបានជំរាល ហើយខ្ចី ឯជើងសក់ខាងក្រោយ ត្រូវអោយនៅចន្លោះចុងស្លឹកត្រចៀកក្រោម និងកអាវ ។ ចំណែកជើងសក់សង្ខាង ត្រូវអោយបានស្តើងហើយត្រង់ មិនត្រូវទុកជើងក្រោមអោយហួសពីពាក់កណ្តាលស្លឹកត្រចៀក ។

យោធិននារីអាចអនុញ្ញាតអោយទុកសក់វែងត្រឹម ប្រះស្មាសមរម្យតាមរង្វង់មួក ដែលត្រូវពាក់ ។

ចំពោះពលទាហាន នាយទាហានរង សិស្សនាយទាហានសកម្ម ត្រូវទុកសក់ ២ ស.ម ។

ចំពោះនាយទាហានចាប់ពីថ្នាក់អនុសេនីយ៍ឡើង ការទុកសក់ត្រូវអោយបានសមរម្យ ។

ចំពោះពលទាហាន នាយទាហានរង និងនាយទាហាន មិនអនុញ្ញាតអោយទុកពុកមាត់ដាច់ខាតលើកលែងតែមានច្បាប់អនុញ្ញាតពិសេស ពីរដ្ឋមន្ត្រីក្រសួងការពារជាតិ ឬពីអគ្គមេបញ្ជាការនៃកងយោធ-ពលខេមរភូមិន្ទ ។

យោធិនទាំងពីរភេទ មិនអនុញ្ញាតអោយទុកក្រចកដៃវែងបានទេ លើកលែងតែយោធិននារីសិល្បៈ ។

**មាត្រា ៣០.-**

ការគំនាប់គឺជាកាតព្វកិច្ច ដែលយោធិនម្នាក់ៗត្រូវធ្វើគារវកិច្ច និងជាការបង្ហាញបញ្ជាក់នូវការគួរសមរបស់យោធិនដែលស្លៀកពាក់ឯកសណ្ឋាន ។ យោធិនក្នុងពេលបំរើការងារត្រូវគំនាប់ដល់យោធិនទាំងឡាយណាដែលមានឋានន្តរស័ក្តិ ឬតួនាទីធំជាងខ្លួន ។ ការគំនាប់នេះគឺជាកាតព្វកិច្ច ដែលយោធិនម្នាក់ៗត្រូវធ្វើដើម្បីសំដែងគារវកិច្ច និងការគួរសមរបស់ខ្លួនដែលស្លៀកពាក់ឯកសណ្ឋាន ។ ការគំនាប់នេះអាចអនុវត្តពីរដងក្នុងមួយថ្ងៃ ព្រឹក ល្ងាច ។

ការគោរពព្រះមហាក្សត្រ និងព្រះសង្ឃ ត្រូវបានចែងលំអិតនៅក្នុងលំហាត់របៀបដោយឡែក ។

យោធិនកាលបើធ្វើដំណើរទៅជួបប្រទះពិធីគោរពទង់ជាតិ ឬទង់កងឯកភាពក្នុងពិធីបុណ្យ ឬហែរក្បួនឬទង់កងឯកភាពបរទេស ត្រូវឈប់ឈរផ្តុំជើងគំនាប់ដោយបែរមុខអោយចំទង់ ។ ប្រសិនបើជួបប្រទះនាវាចំបាំង ដែលមានទង់ជាតិសញ្ញាសំគាល់ ក៏ត្រូវធ្វើគារវកិច្ចដូចគ្នាដែរ ។ ក្នុងពេលចូលរួមពិធីបុណ្យដោយមានការគោរពទង់ជាតិ ឬគ្រាន់តែមានការប្រគុំ ឬចាក់បទភ្លេងជាតិ យោធិនត្រូវក្រោកឈរ ឬឈរប្រុង ហើយគំនាប់លុះត្រាតែចប់បទភ្លេង ទើបសំរាក ឬបន្តដំណើរទៅមុខទៀត ។ គ្រប់ពេលវេលា និងគ្រប់ទីកន្លែង យោធិនណាដែលត្រូវកោះហៅដោយនាយទាហាន ឬនាយទាហានរង ដែលមានឋានន្តរស័ក្តិខ្ពស់ជាង ត្រូវប្រញាប់ប្រញាល់រត់ទៅរកដោយឈរផ្តុំជើងគំនាប់ រីឯយោធិន ដែលត្រូវបានគេគំនាប់ក៏ត្រូវទទួលការគំនាប់វិញដោយសមរម្យ ។

យោធិនក្នុងកងរាជអាវុធហត្ថ ពេលបំពេញមុខងារជាភ្នាក់ងារកម្លាំងសាធារណៈ អាចគំនាប់បាន ប្រសិនបើគ្មានការជាប់រវល់ក្នុងការបំពេញបេសកកម្មរបស់ខ្លួន ។

**មាត្រា ៣១.-**

បើមានថ្នាក់ឧត្តមសេនីយ៍ណាម្នាក់ ចូលទៅក្នុងកន្លែងធ្វើការណាមួយ យោធិនដែលបានក្រឡេកឃើញមុនគេ ត្រូវស្រែកបញ្ជាថា " តាមកន្លែងរៀងខ្លួន គោរព " បើថ្នាក់វរសេនីយ៍ចូលទៅត្រូវស្រែកបញ្ជាថា " តាមកន្លែង គោរព " បើកាលណាអនុសេនីយ៍វិញ ត្រូវស្រែកបញ្ជាថា " គោរព " បើនាយទាហានរងចុះក្រោម ត្រូវស្រែកបញ្ជាថា " ប្រុង " ។

ចំពោះអ្នកទាំងឡាយនៅក្នុងបន្ទប់ ត្រូវប្រញាប់ក្រោកឈរប្រុងយ៉ាងស្ងាត់ស្ងៀម និងស្វាហាប់ រហូតដល់មានបញ្ជាអោយសំរាក ទើបអាចសំរាកបាន ។ ពេលនាយទាហាន នាយទាហានរងទាំងនោះ

ចេញទៅវិញ យោធិនដែលមានឋានន្តរស័ក្តិធំជាងគេ ឬអ្នកប្រចាំការ ឬគ្រូបង្រៀនក្នុងបន្ទប់នោះ ត្រូវស្រែកបញ្ជាថា " ប្រុង " ទោះថ្នាក់ណាក៏ដោយ ។ ប្រសិនជាឧត្តមសេនីយ៍ នាយទាហាន នាយទាហានរងមានគោលបំណងចង់ទុកពេលអោយបុគ្គលិក ឬសិស្សបន្តការងាររបស់គេ ត្រូវអោយដំណឹងជាមុនតាមយោធិនណាម្នាក់ ដែលនៅធ្វើការក្នុងបន្ទប់នោះ ដោយមិនបាច់ស្រែកបញ្ជាអ្វីទាំងអស់ ពេលដែលខ្លួនចូល និងចេញពីបន្ទប់នោះ ជាពិសេសក្នុងទីបញ្ជាការប្រតិបត្តិការសឹក ។

ម្យ៉ាងទៀតបើនៅក្នុងបន្ទប់រៀន ឬក្នុងការិយាល័យ ឬទីលានដែលយោធិនកំពុងស្ថិតនៅជួបជុំគ្នានោះ ក្នុងករណីមាននាយទាហាន ឬនាយទាហានរងណាម្នាក់ដើរចូលមក តែមានឋានន្តរស័ក្តិតូចជាងនាយទាហាន នាយទាហានរង ដែលស្ថិតនៅក្នុងកន្លែងធ្វើការ យោធិនដទៃទៀតមិនត្រូវស្រែកបញ្ជាអោយគោរពជាដាច់ខាត ។ ផ្ទុយទៅវិញបើនាយទាហាន នាយទាហានរង ដើរចូលមកនោះមានមុខងារជាមេបញ្ជាការផ្ទាល់ និងមានឋានន្តរស័ក្តិស្មើគ្នា យោធិននៅទីនោះ ត្រូវតែស្រែកបញ្ជាអោយគោរពជាដាច់ខាត ។

ក្នុងករណីលើទីលាន ប្រសិនបើយោធិនមួយក្រុមឈរ ឬអង្គុយក៏ដោយ ពេលអ្នកមានបណ្ដាស័ក្តិដើរចូលមក យោធិនដែលឃើញមុនគេត្រូវក្រោកឈរ ហើយស្រែកបញ្ជាថា " ប្រុង " ទោះបីអ្នកដើរចូលមក នោះជាថ្នាក់ឧត្តមសេនីយ៍ក៏ដោយ ។

**មាត្រា ៣២.-**

យោធិនគ្រប់រូប ត្រូវធ្វើការគំនាប់ដល់មន្ត្រីរាជការស៊ីវិល ដែលមានមុខដំណែង និងឋានន្តរស័ក្តិខ្ពស់ជាង ។

ចំពោះនាយទាហានបរទេសណា ដែលមានឋានន្តរស័ក្តិខ្ពស់ជាង យោធិននៃកងយោធពលខេមរភូមិន្ទ ត្រូវធ្វើការគោរពដល់ជនបរទេសនោះ ។

**មាត្រា ៣៣.-**

យោធិនគ្រប់រូបក្នុងពេលបំពេញបេសកកម្ម ទស្សនកិច្ចក្នុងកងឯកភាពណាមួយ ត្រូវបង្ហាញខ្លួន និងលិខិតបញ្ជាបេសកកម្មដល់មេបញ្ជាការកងឯកភាព ឬអ្នកតំណាងជាចាំបាច់ ។

**មាត្រា ៣៤.-**

ជាទូទៅក្នុងកន្លែងស្នាក់នៅរបស់យោធាមានជាអាទិ៍ ក្នុងបរិវេណ អាគារ ឬយន្តហោះយោធា ឬនាវា ត្រូវហាមឃាត់ :

- ការលេងល្បែងស៊ីសងគ្រប់ប្រភេទ
- ការនាំចូលដោយគ្មានច្បាប់អនុញ្ញាតនូវគ្រឿងពុល វត្ថុឆាបឆេះ ឬគ្រឿងផ្ទុះ
- ការនាំចូលទស្សនាវដ្តី កាសែត សៀវភៅ ឬការផ្សព្វផ្សាយ ដែលនាំអោយប៉ះពាល់ដល់សីលធម៌ និងវិន័យយោធា ។

**មាត្រា ៣៥.-**

យោធិនត្រូវរក្សាការសំងាត់យោធា និងមិនត្រូវធ្វើអោយឯកសារយោធាបាត់បង់ ឬធ្លាក់ដល់ដៃអ្នកដទៃ ។

ការប្រើប្រាស់ប្រដាប់ថតរូប ថតភាពយន្ត ឬថតសំលេង ព្រមទាំងប៉ុស្តិ៍វិទ្យុផ្សាយសម្លេងទាំងឡាយ ការផ្សព្វផ្សាយ ការលក់ហ្វីលរូបថត ខ្សែអាត់សំលេង នៅក្នុងបរិវេណយោធា អាគារយោធា លើនាវាយោធា និងលើយន្តហោះយោធា ក្នុងពេលប្រតិបត្តិការ ឬបេសកកម្មយោធាចាំបាច់ត្រូវមានការអនុញ្ញាតពីមេបញ្ជាការ ។

**មាត្រា ៣៦.-**

នាយទាហាន ឬនាយទាហានរង ក្នុងពេលចូលរួមបញ្ជាដល់យោធិនទាំងឡាយដែលកាន់អាវុធ ឬក្នុងពេលត្រូវអនុវត្តបេសកកម្មពិសេស ចាំបាច់ត្រូវមានអាវុធជាប់នៅនឹងខ្លួន ។

អាវុធទាំងឡាយ ត្រូវប្រើប្រាស់ជាមួយនឹងឯកសណ្ឋានយោធា ក៏ប៉ុន្តែជួនកាលអាចប្រើជាមួយនឹងឯកសណ្ឋានស៊ីវិលបាន បើកាលណាមានការអនុញ្ញាត ឬណែនាំ ពិសេសពីមេបញ្ជាការ ។

ការកាន់អាវុធ និងការប្រើប្រាស់អាវុធផ្ទាល់ខ្លួន ត្រូវមានការអនុញ្ញាតពី អាជ្ញាធរយោធាមានសមត្ថកិច្ច ។

# ជំពូកទី ៦

## រង្វាន់

**មាត្រា ៣៧.-**

យោធិនគ្រប់រូបដែលបំរើការងារ មានសិទ្ធិទទួលរង្វាន់ដូចៗគ្នា ។ រង្វាន់អាចផ្តល់ជូនចំពោះយោធិនម្នាក់ៗ ក្រុម ឬកងឯកភាព ។ការជូនរង្វាន់ត្រូវផ្អែកលើលក្ខណៈសម្បត្តិដូចខាងក្រោម :

- ជាយោធិនគំរូក្នុងការងារ
- មានស្នាដៃពិសេស មានសេចក្តីក្លាហាន
- ហ៊ានបូជាជីវិតចំពោះប្រយោជន៍រួម ចំពោះប្រទេសជាតិ ។

**មាត្រា ៣៨.-**

រង្វាន់ត្រូវបានចែកចេញជាពីរប្រភេទ គឺរង្វាន់ក្នុងកិច្ចការពិសេស និងរង្វាន់ក្នុងកិច្ចការធម្មតា ។ រង្វាន់ទាំងអស់ត្រូវចុះក្នុងបញ្ជី និងចុះក្នុងសៀវភៅសិក្ខាគារិករបស់យោធិនម្នាក់ៗ ។

គ្រឿងឥស្សរិយយស ត្រូវបានផ្តល់ដល់យោធិនដើម្បីទទួលស្គាល់ស្នាដៃក្នុងការប្រយុទ្ធ មានគុណបំណាច់ខ្ពស់ក្នុងកិច្ចការប្រគល់អោយ ។

ប្រកាសនីយប័ត្រ និងផ្លាកសញ្ញាគ្រឿងឥស្សរិយយស អាចផ្តល់អោយតាមរយៈមេបញ្ជាការ ដើម្បីសំគាល់គុណសម្បត្តិផ្ទាល់ខ្លួន ឬសមត្ថភាពក្នុងការប្រយុទ្ធ ។ មេបញ្ជាការកងយោធពលខេមរភូមិន្ទ អាចផ្តល់រង្វាន់ផ្សេងៗដើម្បីលើកទឹកចិត្តចំពោះលទ្ធផល ដែលបានទទួលក្នុងឱកាសប្រកួតប្រជែង ប្រលងប្រណាំងផ្សេងៗដូចជាលេងកីឡា សិល្បៈ ។ល។ លើកទឹកចិត្តដល់ការប្រឹងប្រែងចំពោះយោធិនណា ដែលធ្វើការងារ អោយមានប្រសិទ្ធភាពជឿនលឿន រីកចំរើនក្នុងការងារ និងសំភារៈផ្សេងៗក្នុងកងទ័ព ។

មេបញ្ជាការទាំងឡាយ ដែលមានសិទ្ធិអនុញ្ញាតច្បាប់ អាចផ្តល់ច្បាប់បន្ថែមបានជារង្វាន់ចំនួន ០៥ថ្ងៃក្នុង ១ឆ្នាំ ដល់យុទ្ធជនលើករណី ដែលត្រូវបានច្បាប់ឈប់សំរាកដូចមានចែងក្នុងមាត្រា១៨ ។

ពលទោ និងនាវិកទោទាំងឡាយ ដែលបានបំពេញមុខងារល្អ ហើយមានការចេះដឹងខាងវិជ្ជាយោធា ត្រូវបានទទួលការតែងតាំងពីមេបញ្ជាការ ជាថ្នាក់ពលឯក ឬនាវិកឯក ដោយមិនគិតពីរយៈពេល ដែលបានចូលបំរើក្នុងកងទ័ពឡើយ ។

**មាត្រា ៣៩.-**

អាជ្ញាធរយោធាដែលមានសិទ្ធិផ្តល់រង្វាន់ដល់យោធិនទាំងឡាយ មានចែងដូចតារាងខាងក្រោម :

| ប្រភេទនៃរង្វាន់ | អាជ្ញាធរដែលអាចផ្តល់រង្វាន់ | | |
|---|---|---|---|
| | មេបញ្ជាការកងទ័ពទាំងបីប្រភេទ ជើងទឹក ជើងគោក ជើងអាកាស មេបញ្ជាការយោធភូមិភាគ មេបញ្ជាការកងរាជអាវុធហត្ថ និងមេបញ្ជាការផ្ទាល់ | អគ្គមេបញ្ជាការ | រដ្ឋមន្ត្រីក្រសួងការពារជាតិ |
| គ្រឿងឥស្សរិយយស និងប្រកាសនីយប័ត្រ | | | |
| ប័ណ្ណសរសើរ | | X | X |
| លិខិតសរសើរ | X | X | X |
| រង្វាន់ជារបស់ ឬជាប្រាក់ | X | X | X |

មេបញ្ជាការផ្ទាល់គឺចាប់ពីថ្នាក់កងពលតូច និងថ្នាក់ប្រហាក់ប្រហែលឡើងទៅ ។

## ជំពូកទី ៧
## ទណ្ឌកម្ម វិន័យ

**មាត្រា ៤០.-**

យោធិនដែលមានការខ្វះខាត និងការធ្វេសប្រហែសក្នុងករណីយកិច្ច ត្រូវទទួលទណ្ឌកម្មផ្នែកវិន័យ និងទទួលទោសតាមច្បាប់ ។

ទណ្ឌកម្មផ្នែកវិន័យ ត្រូវចែងផ្សេងពីទោសល្មើសច្បាប់ ។ កំហុសមួយ អាចទទួលទណ្ឌកម្មផ្នែកវិន័យផង និងទោសតាមច្បាប់ផង ។

ក្រៅពីការព្រមាន ទណ្ឌកម្មផ្នែកវិន័យ ត្រូវចុះក្នុងសៀវភៅសិក្ខាគារិករបស់សាមីយោធិន ។

**មាត្រា ៤១.-**

ទណ្ឌកម្មផ្នែកវិន័យមានដូចចែងខាងក្រោម :

**១-ចំពោះនាយទាហាន និងនាយទាហានរង**

- ការព្រមាន
- ការស្តីបន្ទោស
- ការបន្ទោសដោយលាយលក្ខណ៍អក្សរ ឬ ការផ្អាកមុខដំណែង

**២-ចំពោះពលទាហាន**

- ការព្រមាន
- ការជាប់បញ្ជាក់
- ការផ្អាកមុខដំណែង

**មាត្រា ៤២.-**

ការបន្ថយឋានន្តរស័ក្តិត្រូវធ្វើចំពោះយោធិនដែលមានកំហុសធ្ងន់ និង ប្រព្រឹត្តល្មើសបទប្បញ្ញត្តិច្រើនដង ។ ការបន្ថយឋានន្តរស័ក្តិនេះត្រូវវិនិច្ឆ័យ និងផ្តល់យោបល់ពីក្រុមប្រឹក្សាវិន័យ ។

**មាត្រា ៤៣.-**

យោធិនដែលត្រូវទទួលទណ្ឌកម្មផ្នែកវិន័យ មានសិទ្ធិតវ៉ាពន្យល់ហេតុផលដោយផ្ទាល់មាត់ ឬដោយលាយលក្ខណ៍អក្សរ ចំពោះមេបញ្ជាការឬអ្នកតំណាងដែលបានដាក់ទណ្ឌកម្មនោះ ។

ការដាក់ទណ្ឌកម្ម ត្រូវអនុវត្តទៅតាមអត្រាដាក់ទណ្ឌកម្ម ដូចមានចែងក្នុងឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យនេះ ។

**មាត្រា ៤៤.-**

យោធិនគ្រប់រូបមានសិទ្ធិអំណាច និងករណីយ៍កិច្ចចាប់ទោស និងស្នើសុំផ្តន្ទាទោសជាវិន័យតាមកំរិតថ្នាក់ដល់អ្នកនៅក្រោមបង្គាប់បញ្ជា ដោយធ្វើសំណុំបែបបទ ផ្ញើទៅលំដាប់ថ្នាក់ទទួលខុសត្រូវ ដូចខាងក្រោមនេះ :

- មេបញ្ជាការកងឯកភាពផ្ទាល់
- មេបញ្ជាការយោធភូមិភាគ
- មេបញ្ជាការកងទ័ពជើងគោក ជើងទឹក ជើងអាកាស
- អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ
- រដ្ឋមន្ត្រីក្រសួងការពារជាតិ

តារាងកំរិតសិទ្ធិដាក់ទណ្ឌកម្មជាឧបសម្ព័ន្ធទី ២ នៃអនុក្រឹត្យនេះ ។

**មាត្រា ៤៥.-**

ការព្យួរទោសផ្នែករដ្ឋបាលអាចធ្វើទៅបានក្នុងករណីទណ្ឌកម្មស្រាល ។

មិនអនុញ្ញាតអោយព្យួរទោស ចំពោះយោធិន ដែលត្រូវទទួលទណ្ឌកម្មផ្នែកវិន័យ ច្រើនដងមកហើយ ។

**មាត្រា ៤៦.-**

យោធិនដែលត្រូវដល់កំណត់ឈប់បំរើកងទ័ព ហើយដែលត្រូវជាប់ទណ្ឌកម្ម ត្រូវទទួលទណ្ឌកម្មនោះអោយគ្រប់កំណត់សិន ទើបអាចឈប់បំរើកងទ័ពបាន ។

**មាត្រា ៤៧.-**

កំហុសដែលអាចនឹងត្រូវប្តឹងទៅតុលាការមានជាអាទិ៍ :

**១-កំហុសគេចពីភារកិច្ចយោធា**

- ភាពរឹងរូសមិនគោរពបទបញ្ជា
- យោធិនរត់ចោលជួរ (នៅក្នុងស្រុក)

- ឃោឃិនរត់ចោលជួរ (នៅក្រៅស្រុក)
- ឃោឃិនរត់ចោលជួរដោយមានយកអាវុធទៅជាមួយ
- ឃោឃិនរត់ចោលជួរ នៅចំពោះមុខខ្មាំង ឬចុះចូលខ្មាំង
- ការញុះញង់អោយទាហានរត់ចោលជួរ
- ការរួមគំនិតជាមួយអ្នករត់ចោលជួរ
- ការបំពានលើរូបរាងកាយដោយចេតនា

**២-កំហុសដែលធ្វើអោយប៉ះពាល់ដល់កិត្តិយស និងករណីយកិច្ច**

- ការចុះចាញ់ខ្មាំង
- អំពើក្បត់ជាតិ
- ការប៉ះពាល់ដល់កិច្ចការពារជាតិ
- អំពើប្លន់
- ការរួមគំនិតក្បត់ប្រឆាំង នឹងមេបញ្ជាការជាន់ខ្ពស់
- ការឡើងកាន់មុខដំណែងដោយគ្មានការតែងតាំង
- ការញុះញង់នាំអោយប្រព្រឹត្តិផ្ទុយពីករណីយកិច្ច និងវិន័យយោធា
- ការការពាររថយន្តខុសច្បាប់ និងអំពើរត់ពន្ធផ្សេងៗ
- អំពើលួចលក់ដូរ រត់ពន្ធគ្រឿងញៀន និងបិតិកភ័ណ្ឌជាតិ (វត្ថុបុរាណ)
- ការជីរតយកប្រាក់ពីអ្នកដំណើរ ពីអាជីវករ
- ការចាប់ជំរិតមនុស្សប្តូរយកប្រាក់
- ការបង្ហូចទឹកចិត្តខុសពីសីលធម៌
- ការបំផ្លាញធ្វើអោយបាត់បង់ ឬខូចខាតដោយចេតនា នូវសំភារៈការពារជាតិ
- ការកែបំបាត់ សំភារៈ អាវុធ គ្រាប់រំសេវ រថយន្ត រថពាសដែក សំលៀកបំពាក់ និងសំភារៈផ្សេងៗទៀត
- ការបន្លំលួចសំភារៈសឹក
- ការលួចទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋ

- ការក្លែងបន្លំឯកសណ្ឋាន មេដាយ បដិរូប
- ការកេងប្រវ័ញ្ច ឬក្លែងបន្លំក្នុងកិច្ចការគណនេយ្យ
- ការក្លែងបន្លំនូវគ្រឿងឧបភោគបរិភោគ
- ការបន្លំលួចគ្រឿងបរិក្ខារ បរិក្ខារពេទ្យ និងសំភារៈផ្សេងៗទៀត
- ការលួចតំលើងឋានន្តរស័ក្តិ និងលួចបន្លំចំនួនទ័ព ( ទ័ពខ្មោច)
- ការលួចបន្លំលក់អចលនវត្ថុ សម្បត្តិជាតិ ( ដីធ្លី ផ្ទះសម្បែង)
- ការធ្វើអោយរាំងស្ទះដល់ការអនុវត្តន៍ ដីកា សាលក្រម ឬសាលដីកាស្ថាពររបស់តុលាការគ្រប់ជាន់ថ្នាក់
- និងបទល្មើសដទៃទៀតដែលមានចែងក្នុងច្បាប់ជាធរមាន និងលិខិតបទដ្ឋានពាក់ព័ន្ធ ។

## ៣-កំហុសដែលផ្ទុយនឹងវិន័យយោធា

- ការបះបោរ
- ការបះបោរប្រឆាំងនឹងកំលាំងយោធា និងភ្នាក់ងាររដ្ឋអំណាច
- ការមិនព្រមស្តាប់បង្គាប់ ឬបញ្ជា
- ការរំលោភបំពាននូវច្បាប់កំណែន
- ការបង្កបង្កើតដោយខុសច្បាប់នូវអំណាច ដើម្បីរំលោភទៅលើអ្វីមួយ
- ការប្រព្រឹត្តអំពើឃោរឃៅ ឬប្រមាថយ៉ាងខ្លាំងទៅលើយោធិនក្រោមឱវាទ
- ការប្រមាថជាទម្ងន់ ចំពោះទង់ជាតិ និងកងទ័ព
- ការរំលោភបំពានទៅលើយោធិន អ្នកដែលមានឋានន្តរស័ក្តិធំជាង ( ជេរប្រមាថឬសំឡុតគំរាមកំហែង)
- ការប្រព្រឹត្តអំពើឃោរឃៅចំពោះអ្នកយាមកាម
- ការជេរប្រមាថចំពោះអ្នកយាមកាម
- ការប្រព្រឹត្តអំពើឃោរឃៅបំពាន ជេរសំឡុតដល់ភ្នាក់ងារមន្ត្រីរាជការ ។
- និងបទល្មើសដទៃទៀតដែលមានចែងក្នុងច្បាប់ជាធរមាន និងលិខិតបទដ្ឋានពាក់ព័ន្ធ ។

៤-កំហុសក្នុងការអនុវត្តនឹខុសក្បួនខ្នាតរបស់ក្រសួង

- ការមិនគោរពតាមសេចក្តីបង្គាប់ជាទូទៅ ឬផ្ទាល់ចំពោះយោធិនគ្រប់រូប ដែលមានមុខងារនឹងត្រូវអនុវត្ត

- ការបោះបង់ចោលមូលដ្ឋានប្រយុទ្ធនៅចំពោះមុខខ្មាំង

- ការបោះបង់ចោលមូលដ្ឋាននៅពេលសន្តិភាព

- ការបោះបង់ចោលកន្លែងនៅពេលយាមកាម និងពេលដើរត្រួតពិនិត្យ

- ការបោះបង់ចោល កប៉ាល់ យន្តហោះ

- ការដេកនៅពេលយាមកាម ឬនៅពេលត្រួតពិនិត្យបណ្តាលអោយគ្រោះថ្នាក់ និងបាត់សន្តិសុខក្នុងបន្ទាយ ។

៥-កំហុសនិងការធ្វេសប្រហែសផ្ទាល់ខ្លួន

- ការបំផ្លាញធ្វើអោយបាត់បង់ ឬខូចខាតនូវអាគារធំៗ កប៉ាល់ យន្តហោះ រថពាសដែក សព្វាវុធយោធា និងគ្រឿងបំពាក់យោធាដោយមានការធ្វេសប្រហែស

- កំហុសក្នុងការផលិត ឬកែឆ្នៃប្រឌិតដើម្បីធ្វើអាជីវកម្ម នូវអាវុធគ្រាប់រំសេវគ្រឿងផ្ទុះផ្សេងៗ ។

៦-កំហុសផ្សេងៗទៀតមានជាអាទិ:

- ការអោយបញ្ជាដោយខុសច្បាប់

- ការប្រព្រឹត្តអំពើទុច្ចរិត

- ការរៀបចំទុកដាក់ឯកសារមិនត្រឹមត្រូវ (ធ្វើអោយបាត់បង់ ឬធ្លាក់ដល់ដៃអ្នកដទៃ)

- ការធ្វើអោយប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើភាពថ្លៃថ្នូររបស់កងទ័ព

- ការធ្វេសប្រហែសដោយមិនយកចិត្តទុកដាក់ប្រុងប្រយ័ត្ន ក្នុងកិច្ចការដែលនាំអោយមានគ្រោះ-ថ្នាក់ដល់អាយុជីវិត និងខូចខាតសំភារៈយ៉ាងច្រើន ។

**មាត្រា ៤៨.-**

អំពើល្មើសពាក់ព័ន្ធទៅនឹងច្បាប់ចរាចរដូចខាងក្រោមត្រូវទទួលទោសតាមវិន័យយោធាផង នឹងអាចត្រូវបញ្ជូនទៅតុលាការ

- ការបើកបរដោយស្រវឹងស្រា
- ការរត់គេចក្រោយពេលមានគ្រោះថ្នាក់
- ការប្រជែងរថយន្តដោយខុសច្បាប់
- ការមិនគោរពសិទ្ធិអ្នកបើកបរ ដែលគេមានសិទ្ធិជាង
- ការមិនគោរពភ្លើងសញ្ញាចរាចរ
- ការបើកល្បឿនហួសកំណត់
- ការបត់ ឬត្រលប់ដោយគ្មានសញ្ញាសំគាល់
- ការមិនគោរពតាមការនែកនេរតាមផ្លូវ
- ការមិនគោរពគំនូសចរាចរ ដែលកំណត់តាមផ្លូវ
- ការមិនគោរពសិទ្ធិអ្នកមានអាទិភាពមកពីខាងស្តាំ
- ការចតរថយន្តនៅជិតផ្លូវខ្វែង
- ការបើកភ្លើងហ្វា ដែលនាំអោយចាំងភ្នែកគេ
- ការឈប់រថយន្តនៅខាងឆ្វេងដៃ
- ការមិនព្រមងាកស្តាំ ដោយមានរថយន្តសុំប្រជែង
- ការងាកស្តាំរហ័សពេក ក្រោយពេលប្រជែងរថយន្តមុខរួច
- ព្រមទាំងបទល្មើស នឹងច្បាប់ចរាចរ និងលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងទៀត ។

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**មាត្រា ៤៩.-**

បទបញ្ញាទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥០.-**

រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងការពារជាតិ អគ្គមេបញ្ជាការ នៃកង-យោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៥១.-**

អនុក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្ដេច នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥០
- ឯកសារ-កាលប្បវត្តិ